CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 13 ខែឧសភា ឆ្នាំ 2021
ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS (6397), jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# នាយកដ្ឋានសុខាភិបាល ផ្តល់ជំនួយ ផ្នែកចុះឈ្មោះទទួលធានារ៉ាប់រងវេជ្ជសាស្ត្រ របស់រដ្ឋ

## *កម្មវិធីធានារ៉ាប់រង កាលីហ្វ័រញ៉ា ប្រកាសពី គន្លងថ្មី ដើម្បីទទួលបានធានារ៉ាប់រង*

ឡុងប៊ិច, CA - នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស ឡុងប៊ិច (នាយកដ្ឋានសុខាភិបាល) នឹងផ្តល់ជំនួយ ផ្នែកចុះឈ្មោះ ដល់អ្នកដែលអាចមានសិទ្ធិទទួលបាន ធានារ៉ាប់រង កាលីហ្វ័រញ៉ា និង Medi-Cal ។ កម្មវិធី ដែលប្រតិបត្តិការ ដោយរដ្ឋ ទាំងនេះ ផ្តល់ លទ្ធភាពទទួលបាន ការថែទាំបឋម, ការព្យាបាល ករណីសង្គ្រោះ បន្ទាន់ និងសេវាសុខភាពផ្លូវចិត្ត ជូនអ្នកគ្រប់គ្នា ដែលមានសិទ្ធិអាចទទួលបាន ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) បានបញ្ជាក់ថា «ជាផ្នែក នៃផែនការសង្គ្រោះ ពលរដ្ឋអាមេរិក ថ្លៃចំណាយធានារ៉ាប់រងសុខភាពនឹងមានផ្តល់ជូន ដោយគ្មានដែនកម្រិត តាមកម្រិតចំណូល ឬ បុរេលក្ខខណ្ឌ និងកំណត់សម្រាប់តែធានារ៉ាប់រង ក្នុងកម្រិតថ្លៃទាបនោះទេ ។»

នាពេលថ្មីៗ នេះ កម្មវិធីធានារ៉ាប់រង កាលីហ្វ័រញ៉ា បានប្រកាសថា អ្នកប្រើប្រាស់ ដែលមានសិទ្ធិអាច ទទួលបានទាំងអស់ នឹងអាចចុះឈ្មោះបាន នៅចុងឆ្នាំនេះ ។

ជំនួយ មានផ្តល់ជូន ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច នៅថ្ងៃធ្វើការ តាមរយៈលេខ 562.570.7979 ។ គ្រូប្រឹក្សាផ្នែកចុះឈ្មោះ ដែលមានវិញ្ញាបនបត្របញ្ជាក់ ចេះនិយាយភាសា អង់គ្លេស អេស្ប៉ាញ និង ខ្មែរ ហើយអាចប្រើ ភាសាតាហ្គាឡុក និងភាសាផ្សេងៗទៀត ។ ចម្ងល់នានា អាចបញ្ជូន ទៅ coveredlb@longbeach.gov បាន ។

អ្នកដែលបានចុះឈ្មោះ តាមរយៈកម្មវិធីធានារ៉ាប់រង កាលីហ្វ័រញ៉ា នឹងអាចមាន ផែនការធានារ៉ាប់រង សុខភាពឯកជន បាន ។ ថ្លៃបុព្វលាភ ប្រចាំខែ នឹងមានកម្រិតទាប ជាសារវ័ន្ត សម្រាប់ប្រជាពល រដ្ឋកាលីហ្វ័រញ៉ា ប្រមាណ 2.5 លាន នាក់ ដោយសារការចាក់បញ្ចូលឧបត្ថម្ភធន ផ្នែកថែទាំសុខភាព ចំនួន $3 ពាន់លាន ពីផែនការសង្គ្រោះពលរដ្ឋអាមេរិក។ លើសពីនេះទៅទៀត បុគ្គលម្នាក់ៗ ដែលទទួលបាន អត្ថប្រយោជន៍ធានារ៉ាប់រងពេលគ្មានការងារធ្វើ (UIB) នឹងទទួលបាន ជំនួយបន្ថែម ដើម្បីអាចទទួលបាន ថ្លៃបុព្វលាភ ប្រចាំខែ និង ថ្លៃចំណាយចេញពីហោប៉ៅ ក្នុងកម្រិតទាបជាងមុន ។ អ្នកប្រើប្រាស់ទាំងនេះ អាចទិញ ធានារ៉ាប់រង កម្រិតសំរិទ្ធិ ក្នុងថ្លៃ ត្រឹមតែ $1 ក្នុងមួយខែ បាន ។ ក្រោយពេលជ្រើសយកផែនការរួច នោះជំនួយរ៉ាប់រងរបស់ពួកគេ នឹងចាប់ផ្តើមមានសុពលភាព នៅថ្ងៃទីមួយ នៃខែបន្ទាប់ ។

CITY OF LONG BEACH

# PRESS RELEASE

**កម្មវិធី Medi-Cal**
អ្នកប្រើប្រាស់ ដែលបានចុះឈ្មោះ តាមរយៈ [CoveredCA.com](http://CoveredCA.com) អាចកំណត់មើល ថាតើអាចមានសិទ្ធិទទួលបាន ធានារ៉ាប់រង ដោយឥតគិតថ្លៃ ឬដោយមានថ្លៃទាប តាមរយៈ Medi-Cal ដែលពួកគេអាចចុះឈ្មោះ តាមអ៊ីនធឺណែតបាន ឬអត់នោះ ។ អ្នកដែលមានសិទ្ធិអាចទទួលបាន Medi-Cal អាចទទួលបាន ធានារ៉ាប់រង ដែលមានសុពលភាព បានភ្លាមៗ ។ កាលីហ្វ័រញ៉ា បានផ្អាកការវាយតម្លៃ លើការបន្តសិទ្ធិទទួលបាន Medi-Cal និង ការឈប់បន្ត រហូតដល់ពេលបញ្ចប់កាលអាសន្ន ផ្នែកសុខភាពសាធារណៈ ដោយធានាឱ្យ អ្នកដែលបានចុះឈ្មោះរួច អាចបន្តទទួលបាន ធានារ៉ាប់រង របស់ពួកគេដដែល ។

**គ្លីនិកវាយតម្លៃរហ័ស (RAC)**
ប្រសិនបើលោកអ្នកមានជំងឺ ដែលតម្រូវឱ្យមាន ការមើលថែ ផ្នែកវេជ្ជសាស្ត្រ មុនពេលធានារ៉ាប់រងសុខភាព របស់លោកអ្នក ចាប់មានសុពលភាពនោះ សូមចូលទៅ គ្លីនិកវាយតម្លៃរហ័ស (RAC) ដែលជាគ្លីនិកផ្តល់ការវាយតម្លៃ និងការព្យាបាល ដោយឥតគិតថ្លៃ សម្រាប់ជំងឺទូទៅ ដូចជា ជំងឺត្រចៀក និងការឆ្លងរោគ នៅផ្នែកតម្រងនោម ។ RAC ក្នុងបរិវេណនៅតំបន់ឆ្នេរប៉ាស៊ីហ្វិក របស់មហាវិទ្យាល័យក្រុងឡុងប៊ិច (1305 ផ្លូវហាយវេ ឆ្នេរប៉ាស៊ីហ្វិកខាងកើត) បើកដំណើរការ ពីម៉ោង 10 ព្រឹក ដល់ម៉ោង 1 រសៀល នៅថ្ងៃធ្វើការ ក្នុងសប្តាហ៍ ។ មិនចាំបាច់មាន ការណាត់ជួបទុកជាមុន នោះទេ ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ ដែលសាលាក្រុងឡុងប៊ិច កំពុងអនុវត្ត ដើម្បីរក្សាឱ្យប្រជាពលរដ្ឋ មានសុវត្ថិភាពនោះ សូមចូលទៅ [longbeach.gov/COVID19](http://longbeach.gov/COVID19) ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #